**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Dec-2012, 12:44
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/**Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ អៀង សារី អំពីបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងសេចក្ដីសម្រេចស្ដីពីវិសាលភាពនៃការជំនុំជម្រះក្ដី នៅក្នុងសំណុំរឿងលេខ០០២/០១**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្ដម
លោក Michael G.KARNAVAS
លោក គង់ សំអុន

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក Anta GUISSE |
| ពេជ អង្គ | លោក Arthur VERCKEN |
| Elisabeth SIMONNEAU FORT | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាដាក់ជូននូវការឆ្លើយតបដូចខាងក្រោមនេះ ចំពោះចម្លើយតបរបស់ អៀងសារី ទៅនឹងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១("ចម្លើយតប")[1]។ ក្នុងខណៈដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យបើកសវនាការផ្ទាល់មាត់មួយ ឬជាជំនួស សុំការអនុញ្ញាតដើម្បីដាក់ការឆ្លើយតបរួមទៅនឹងចម្លើយតបរបស់ជនជាប់ចោទទាំងបីរូប[2] អង្គជំនុំជម្រះតុលាការកំពូលនៅមិនទាន់បានធ្វើការសម្រេចនៅលើសំណើនោះនៅឡើយទេ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាដាក់ជូននូវការឆ្លើយតបនេះ ដើម្បីធានាឱ្យប្រាកដថា សហព្រះរាជអាជ្ញាមិនលះបង់សិទ្ធិរបស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងចម្លើយតបដែលបានដាក់ដោយមេធាវីការពារក្តីរបស់ អៀង សារី ឡើយ[3]។

## II. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា គឺធ្វើឡើងទាន់ពេលវេលា និងអាចទទួលយកបាន

២- ចម្លើយតបនេះមិនបានតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងបានមានកំហុសឆ្គងដោយបានដកទីតាំងឧក្រិដ្ឋកម្មនៃស្រុក១២ និងមន្ទីរស-២១ ចេញពីវិសាលភាពនៃសវនាការជំនុំជម្រះក្តី លើសំណុំរឿងលេខ០០២/០១នោះឡើយ។ ផ្ទុយទៅវិញ មេធាវីការពារក្តី អៀង សារី បានកម្រិតជំទាស់របស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទៅលើអំណះអំណាងអំពីភាពទាន់ពេលវេលា និងភាពអាច

[1] ឯកសារលេខ **E 163/5/1/3** ចម្លើយតបរបស់ អៀង សារី ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាចំពោះសេចក្តីសម្រេចទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី១៩ វិច្ឆិកា ២០១២ ("ចម្លើយតប")។

[2] ឯកសារលេខ **E163/5/1/6** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ ឬជាជំនួស ស្នើសុំឱ្យដាក់ការឆ្លើយតបរួមមួយទៅនឹងចម្លើយតបរបស់មេធាវីការពារជនជាប់ចោទទាំងបីក្រុម, ចុះថ្ងៃទី២១ វិច្ឆិកា ២០១២។

[3] ចម្លើយតបរបស់ អៀង សារី ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស ចុះថ្ងៃទី២០ វិច្ឆិកា ២០១២ និងជាភាសាខ្មែរ ចុះថ្ងៃទី២១ វិច្ឆិកា ២០១២, ដូចនេះ ការឆ្លើយតបទៅនឹងចម្លើយតបនោះ គឺត្រូវដល់ថ្ងៃកំណត់នៅថ្ងៃទី២៦ វិច្ឆិកា ២០១២។ មកទល់នឹងថ្ងៃនេះ ចម្លើយតបរបស់មេធាវីការពារក្តី នួន ជា (ឯកសារលេខ**E163/5/1/4**) ត្រូវបានជូនដំណឹងតែភាសាអង់គ្លេសប៉ុណ្ណោះ។ មេធាវីការពារក្តី ខៀវ សំផន ត្រូវបានអនុញ្ញាតឱ្យពន្យារពេល, ចម្លើយតបរបស់ពួកគេមិនទាន់ដល់ពេលកំណត់នៅឡើយ លុះត្រាតែដល់ថ្ងៃទី៣០ វិច្ឆិកា ២០១២ ឯកសារលេខ **E163/5/1/2/1** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី២០ វិច្ឆិកា ២០១២។

ទទួលយកបាននៃបណ្តឹងសាទុក្ខនេះ។ ហេតុដូចនេះ សហព្រះរាជអាជ្ញានឹងកម្រិតនូវការឆ្លើយតបរបស់ខ្លួនទៅលើបញ្ហាទាំងអស់នោះ។ សហព្រះរាជអាជ្ញានឹងមិនឆ្លើយតបទៅនឹងការវាយប្រហារ ដែលសំដៅប្រឆាំងនឹងសហព្រះរាជអាជ្ញាអន្តរជាតិដូចមាននៅក្នុងចម្លើយតបនេះ[4] ជាងការកត់សម្គាល់ថាការវាយប្រហារទៅលើបុគ្គលនោះគឺមិនសមស្របទេ ហើយមិនពាក់ព័ន្ធទាល់តែសោះទៅនឹងបញ្ហានៅក្នុងបណ្តឹងសាទុក្ខ និងជាសញ្ញាបង្ហាញឲ្យឃើញពីកង្វះខ្លឹមសារនៅក្នុងអំណះអំណាងរបស់មេធាវីការពារក្តី។

## ក. ការសម្រេចរបស់អង្គជំនុំជម្រះលើការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពនៃសវនាការជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ០០២/០១ គឺមិនទាន់បានចប់សព្វគ្រប់ទេរហូតទល់នឹងសេចក្តីសម្រេច ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២

៣- មេធាវីការពារក្តីបានលើកអំណះអំណាងដំបូងថា បណ្តឹងសាទុក្ខនេះត្រូវបានរារាំងដោយពេលវេលាពីព្រោះសហព្រះរាជអាជ្ញាគួរតែបានធ្វើបណ្តឹងសាទុក្ខនេះប្រឆាំងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឬប្រឆាំងនឹងការបដិសេធលើសំណើសុំឲ្យពិនិត្យឡើងវិញ[5]។

៤- ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាមិនបានប្តឹងសាទុក្ខចំពោះសេចក្តីសម្រេច ឬដីកាសម្រេចពីមុនៗឡើយ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងមិនបានកំណត់សម្រេចជាចុងក្រោយលើវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ និងលើទីតាំងឧក្រិដ្ឋកម្មបន្ថែមដែលគួរដាក់បញ្ចូលរហូតមកដល់សេចក្តីសម្រេចដែលរងការជំទាស់នោះឡើយ។ នៅក្នុងដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដំបូង អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថាខ្លួន "ធ្វើការសម្រេចនៅពេលណាមួយក៏បាន ដើម្បីដាក់បញ្ចូលក្នុងសវនាការលើកដំបូង នូវផ្នែកបន្ថែមណាមួយនៃដីកាដំណោះស្រាយក្នុងសំណុំរឿងលេខ០០២"[6]។ នៅក្នុងសេចក្តីសម្រេចស្តីពីការពិនិត្យឡើងវិញរបស់ខ្លួនមួយខែបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជាថ្មីម្តងទៀតថាខ្លួន "មិនដកចោលនូវលទ្ធភាព ក្នុងការដាក់បន្ថែមនូវការចោទប្រកាន់ ឬបទចោទក្នុងសវនាការជំនុំជម្រះក្តីលើកដំបូងនៅក្នុងសំណុំរឿងលេខ០០២

[4] ឯកសារលេខ **E163/5/1/3** ចម្លើយតប, កថាខណ្ឌទី១៦ (លេខយោងជើងទំព័រលេខ៣៣), កថាខណ្ឌទី៥៨។

[5] ឯកសារលេខ **E163/5/1/3** ចម្លើយតប, កថាខណ្ឌទី២១-២៩។

[6] ឯកសារលេខ **E124** ដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ*, ចុះថ្ងៃទី២២ កញ្ញា ២០១១, កថាខណ្ឌទី៦។

នោះឡើយ ប្រសិនកាលៈទេសៈអនុញ្ញាត”[7]។ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់អំពីសំណើរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ដែលសុំឱ្យដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មចំនួនបីបន្ថែមទៀត[8] និងបានឆ្លើយតបថាខ្លួន “អាចសម្រេចតាមការយល់ឃើញដោយផ្ទាល់ នៅក្នុងពេលសមស្របណាមួយ ដើម្បីពង្រីកវិសាលភាពនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿងលេខ០០២/០១”[9]។

៥- ក្នុងខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាថា ខ្លួនកំពុងតែពិនិត្យលើ “ការពង្រីកក្នុងលក្ខណៈសាមញ្ញ”មួយ នូវវិសាលភាពនៃការជំនុំជម្រះក្ដី ដើម្បីដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មចំនួនបីដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា ក្នុងខែមករា ឆ្នាំ២០១២ -គឺទីតាំងសម្លាប់មនុស្សនៅស្រុក១២ និងទួលពោធិ៍ជ្រៃ និងមន្ទីរសន្តិសុខស-២១[10]។ ផ្ទុយពីអំណះអំណាងដែលបានធ្វើឡើងដោយមេធាវីការពារក្ដីដូចមានក្នុងចម្លើយតបរបស់ពួកគេ គឺអង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនមិនទាន់បានធ្វើការសម្រេចបញ្ចប់នៅឡើយទេ ហើយកំពុងតែពិនិត្យលើសំណើចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សហព្រះរាជអាជ្ញា នៅឡើយ៖ “ទោះបីជាការផ្ដោតជាសំខាន់នៃការខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះមកទល់ពេលនេះ គឺដើម្បីធានាក្នុងការធ្វើឱ្យកាន់តែប្រសើរឡើង និងការជំនុំជម្រះក្ដីប្រកបដោយប្រសិទ្ធភាព”ខ្លាំងថែមទៀត ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះក៏បានលះបង់ផងដែរនូវពេលវេលា និងធនធានដើម្បីធ្វើការវាយតម្លៃអំពីផលប៉ះពាល់នៃការយល់ព្រមទទួល

---

[7] ឯកសារលេខ **E124/7** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិនិត្យឡើងវិញលើពាក្យពេចន៍ក្នុងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារលេខE124/2) និងញត្តិព្រមទាំងឧបសម្ព័ន្ធនានាដែលទាក់ទង, ចុះថ្ងៃទី១៨ តុលា ២០១១, កថាខណ្ឌទី១២។

[8] ឯកសារលេខ **E163** សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី២៧ មករា ២០១២។

[9] ឯកសារលេខ **E172** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា “ក្រុមសាក្សី, ក្រុមដើមបណ្ដឹងរដ្ឋប្បវេណី, និងក្រុមអ្នកជំនាញបន្ទាប់ទៀតដែលត្រូវស្ដាប់ចម្លើយ នៅក្នុងសំណុំរឿងលេខ០០២/០១”, ចុះថ្ងៃទី១៧ កុម្ភៈ ២០១២, ទំព័រ៤។

[10] ឯកសារលេខ **E218** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់នៅក្នុងសំណុំរឿងលេខ០០២/០១ និងការអនុវត្តវិធានការបន្ថែមសម្រាប់លើកកំពស់ប្រសិទ្ធភាពនៃសវនាការ”, ចុះថ្ងៃទី៣ សីហា ២០១២, កថាខណ្ឌទី១៣។ ឯកសារលេខ **E218.1** ឧបសម្ព័ន្ធភ្ជាប់នឹងអនុស្សរណៈដែលមានចំណងជើងថា៖ “សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពង្រីកវិសាលភាពនៃសវនាការ នៅក្នុងសំណុំរឿងលេខ០០២/០១ (ឯកសារលេខ E163),” ចុះថ្ងៃទី៣ សីហា ២០១២, កថាខណ្ឌទី១-៥។

យកសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យពង្រីកវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ដូចបានស្នើនៅក្នុងឯកសារលេខE163”[11]។

៦- អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើសេចក្តីសម្រេចជាស្ថាពរ និងជាក់លាក់លើវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១នៅឡើយ ដែលក្នុងនោះរួមមាន ថាតើទីតាំងឧក្រិដ្ឋកម្មណាខ្លះគួរត្រូវដាក់បញ្ចូល និងទីតាំងឧក្រិដ្ឋកម្មណាខ្លះគួរត្រូវដកចេញ រហូតមកទល់នឹង“ការជូនដំណឹងអំពីសេចក្តីសម្រេចចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ លើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១ ឯកសារ E163”[12]។

៧- អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ពេលវេលាសម្រាប់ដាក់បណ្តឹងសាទុក្ខ គឺមិនទាន់ចាប់ផ្តើមគិតនៅឡើយទេ រហូតទៅដល់អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចពេញលេញទាំងស្រុងមួយដែលសម្រេចបញ្ចប់អំពីបញ្ហាទាំងឡាយដែលភាគីបានស្នើឡើងតាមសំណើជាមុនសិន។ ក្នុងការសម្រេចថា ពេលវេលារបស់មេធាវីការពារក្តី នួន ជា សម្រាប់ប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនមែនធ្វើឡើងដោយការសម្រេចដោយផ្ទាល់មាត់កាលពីមុននោះទេ អង្គជំនុំជម្រះនេះបានកត់សម្គាល់ថា សេចក្តីសម្រេចរបស់តុលាការត្រូវតែ “សម្រេចបញ្ចប់លើបញ្ហាអង្គច្បាប់នៅចំពោះមុខ ក្នុងលក្ខណៈច្បាស់លាស់មួយ” ហើយថាសេចក្តីសម្រេចដើមដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងមិន “ពេញលេញ”បានទេ រហូតទាល់តែ “ការសម្រេចជាលាយលក្ខណ៍អក្សរបន្តបន្ទាប់ដែលបានដោះស្រាយ និងបានសម្រេចពេញលេញ ដោយអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង ចំពោះបញ្ហាដែលមេធាវីការពារក្តីបានលើកឡើង”[13]។ នៅក្នុងបញ្ហាចំពោះមុខនេះ អង្គជំនុំ

[11] ឯកសារលេខ **E218** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១៣។

[12] ឯកសារលេខ **E163/5** សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ០០២/០១ (ឯកសារលេខE163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមានដែលជាផ្នែកនៃដីកាដំណោះស្រាយ, ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២, កថាខណ្ឌទី១-៣ (“ដើម្បីសម្រួលដល់ភាគីនានាក្នុងការរៀបចំផែនការ និងផ្តល់នូវភាពជាក់លាក់ពាក់ព័ន្ធនឹងផ្នែកដែលនៅសេសសល់ ក្នុងសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងធ្វើសវនាការនាពេលខាងមុខនេះ, អង្គជំនុំជម្រះសាលាដំបូងមានបំណងជូនដំណឹងទៅភាគី និងសាធារណជន អំពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្តី ”)។

[13] ឯកសារលេខ **E176/2/1/4** សេក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៤ កញ្ញា ២០១២, កថាខណ្ឌទី២៥-២៧។

ជម្រះមិនបានធ្វើសេចក្តីសម្រេចពេញលេញ និងដាក់លាក់លើវិសាលភាពនៃការជំនុំជម្រះក្តី ក្នុងសំណុំរឿងលេខ០០២/០១ទេ រហូតដល់ពេលចេញសេចក្តីសម្រេចដែលរងការជំទាស់ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២។

៨- សេចក្តីសម្រេចដែលរងការជំទាស់ ត្រូវបានជូនដំណឹងទៅភាគីនានាបានជ្រាបតាមរយៈអនុស្សរណៈមួយ។ មេធាវីការពារក្តីរបស់ អៀង សារី កាលពីមុន ធ្លាប់បានទទួលស្គាល់ថា អនុស្សរណៈ "មានតួនាទីជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលអាចបើកឱ្យប្តឹងសាទុក្ខបាន អនុលោមតាមវិធាន ១០៤" ដោយបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង "តែងតែចេញសេចក្តីសម្រេចជាប្រក្រតីតាមទម្រង់នេះ"[14]។ អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានបញ្ជាក់ថាអនុស្សរណៈបែបនេះ គឺជា "សេចក្តីសម្រេច"ដែលត្រូវបាន "ចេញតាងនាមឱ្យអង្គជំនុំជម្រះទាំងមូល" អនុលោមទៅតាម "ទម្លាប់អនុវត្តដែលធ្លាប់បានស្គាល់កន្លងមកនៅចំពោះមុខទាំងតុលាការកម្ពុជា និងតុលាការអន្តរជាតិដទៃទៀត"[15]។ នៅក្នុងខណៈនេះ ចំណងជើងនៃអនុស្សរណៈខ្លួនឯងផ្ទុះបញ្ចាំងអំពីរឿងនេះ មានន័យថា ជាសេចក្តីជូនដំណឹងអំពី*សេចក្តីសម្រេច*។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងយោងស្របទៅនឹងអនុស្សរណៈបែបនេះ ថាជា "សេចក្តីសម្រេច" នៅក្នុងឱកាសនីមួយៗដែលត្រូវបានប្តឹងសាទុក្ខដោយមេធាវីការពារក្តី[16]។

៩- អាស្រ័យហេតុនេះ មិនអាចមានបញ្ហាចោទទេថា "សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ លើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំ

[14] ឯកសារលេខ **E154/1/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ រក្សារការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់, ចុះថ្ងៃទី២០ មករា ២០១២ កថាខណ្ឌទី១-២។

[15] ឯកសារលេខ **E74** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងញត្តិដែលមានឯកសារលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និងលេខ E73 បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១, កថាខណ្ឌទី៣-៤។

[16] ឯកសារលេខ **E154/1/1/4** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ធ្វើការការប្រាស្រ័យទាក់ទងជាមួយភាគីតែម្ខាង, ចុះថ្ងៃទី២៥ មេសា ២០១២។ ឯកសារលេខ **E9/7/1/1/1/4** សេចក្តីសម្រេចស្តីពីការជូនដំណឹងពីរអំពីបណ្តឹងសាទុក្ខដែលដាក់ដោយ អៀង សារី, ចុះថ្ងៃទី៨ មេសា ២០១១ [ដែលយោងទៅលើឯកសារលេខ E9/7/1 ថាជាសេចក្តីសម្រេចមួយ ក្នុងចំណោម "សេចក្តីសម្រេចនានាដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង"]។ ឯកសារលេខ **E62/3/10/5/1** សេចក្តីសម្រេចលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២០ កញ្ញា ២០១១ [ដែលយោងទៅលើឯកសារលេខ E62/3/10/4 ថាជា "សេចក្តីសម្រេចមួយដោយអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងសិទ្ធិក្នុងការមើលរបាយការណ៍វេជ្ជសាស្ត្រ"]។

ដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម” គឺជាសេចក្តីសម្រេចមួយដែលត្រូវប្តឹងសាទុក្ខនោះ ហើយបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាត្រូវដាក់នៅក្នុងរយៈពេលកំណត់៣០ថ្ងៃ តាមវិធាន១០៧(១)។

### ខ. សេចក្តីសម្រេចដែលបញ្ចប់ដោយប្រសិទ្ធភាពនូវការចោទប្រកាន់ពីឧក្រិដ្ឋមួយចំនួន គឺត្រូវស្ថិតនៅក្រោមការពិនិត្យឡើងវិញ លើបណ្តឹងសាទុក្ខភ្លាមៗ ផ្អែកតាមវិធាន១០៤(ក)នៃវិធានផ្ទៃក្នុង

១០- សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា នៅគ្រប់ការដាក់សេចក្តីសន្និដ្ឋានទាំងអស់ពីមុនមកដែលខ្លួនបានដាក់ជូនអង្គជំនុំជម្រះ ហេតុផលដែលនាំឲ្យធ្វើការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខភ្លាមៗនេះ គឺកម្រិតត្រឹមតែហេតុផលដូចដែលបានចែងនៅក្នុងវិធាន១០៤(៤)ប៉ុណ្ណោះ។ ផ្ទុយទៅវិញ មេធាវីការពារក្តី អៀង សារី បានជំទាស់ម្តងហើយម្តងទៀតនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនថា ទាំងវិធាន១០៤(១) និងទាំងវិធាន២១ បានចែងអំពីហេតុផលដាច់ផ្សេងពីគ្នាសម្រាប់បណ្តឹងសាទុក្ខលើបញ្ហាបន្ទាន់បន្ទំ[17]។ ទាក់ទងទៅនឹងវិធាន១០៤(៤) មេធាវីការពារក្តីបានលើកអំណះអំណាងស្របចំពោះ “ការបកស្រាយទូលំទូលាយអំពីសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខភ្លាមៗ”[18]។

---

[17] សូមអាន ឧទាហរណ៍ដូចជា ឯកសារលេខ **E9/7/1/1/1/2** ការឆ្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជូនដំណឹងពីររបស់ អៀង សារី ស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើសំណើសុំបន្ថែមពេលវេលាកំណត់ និងចំនួនទំព័រកំណត់ សម្រាប់ការដាក់អញ្ញត្រកម្មបឋម, ចុះថ្ងៃទី២២ មីនា ២០១១, កថាខណ្ឌទី២-៣។ ឯកសារលេខ **E154/1/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធលើសំណើរបស់ លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់, ចុះថ្ងៃទី២០ មករា ២០១២ កថាខណ្ឌទី៣-៧ និង១១។

[18] ឯកសារលេខ **E130/4/1**បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការក្នុងអម្លុងពេលជំនុំជម្រះក្តី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញ ក្នុងការទទួលបានការជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់, ចុះថ្ងៃទី៥ មករា ២០១២, កថាខណ្ឌទី១១ ។ ឯកសារលេខ **E95/8/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំដកលក្ខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី២៥ វិច្ឆិកា ២០១១, កថាខណ្ឌទី១៦។ ឯកសារលេខ **E154/1/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់, ចុះថ្ងៃទី២០ មករា ២០១២ កថាខណ្ឌទី៤។

១១- ក្នុងខណៈដែលអង្គជំនុំជម្រះតុលាការកំពូលបានកម្រិតលើបណ្ដឹងសាទុក្ខភ្លាមៗ ត្រឹមតែហេតុផលដូចដែលមានចែងនៅក្នុងវិធាន១០៤(៤)នោះ អង្គជំនុំជម្រះនេះមិនបានធ្វើបកស្រាយដោយម៉ឺងម៉ាត់ឬដោយន័យចង្អៀតចំពោះហេតុផលទាំងនោះឡើយ ប៉ុន្តែផ្ទុយទៅវិញ បានសម្រេចជ្រើសយកវិធីសាស្ត្រមួយដែលមានចេតនា បានពិនិត្យមើលអំពីសនិទានភាពនៃវិធានផ្ទៃក្នុង និងបានពិចារណាថាតើសិទ្ធិរបស់ភាគីនានាអាចត្រូវបានប៉ះពាល់យ៉ាងដូចម្ដេច បើសិនជាត្រូវបានកម្រិតត្រឹមការប្ដឹងសាទុក្ខនៅក្រោយការចេញសាលក្រម[19]។ ហេតុដូចនេះ នៅក្នុងការកំណត់សម្រេចអំពីភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី អនុលោមតាមវិធាន១០៤(៤)(ឃ) ដែលអនុញ្ញាតឱ្យប្ដឹងសាទុក្ខភ្លាមៗអំពី "សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ តាមវិធាន៣៥(៦)" នោះអង្គជំនុំជម្រះមិនបានបកស្រាយថាបទប្បញ្ញត្តិនេះត្រូវបានកម្រិតយ៉ាងតឹងតែងមកត្រឹមសេចក្ដីសម្រេចដែលមានចំណងជើងថា "សេចក្ដីសម្រេចស្ដីពីការ ជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ" ឬសំណើដែលបានផ្អែកយ៉ាងច្បាស់លើមូលដ្ឋាននៃវិធាន៣៥(៦)[20]។ ជាងនេះទៀត អង្គជំនុំជម្រះបានអនុវត្តតេស្ដមួយដែលចង់បានខ្លឹមសារជាងទម្រង់ និងពិចារណាថាតើសំណើដែលជាដើមចម "យ៉ាងហោចណាស់ មួយផ្នែក អាចត្រូវបានកំណត់ថាជាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន៣៥ដែរ" ដោយចាត់ទុកថាបណ្ដឹងសាទុក្ខបែបនេះអាចឱ្យទទួលយក

---

[19] ឯកសារលេខ **E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ធ្វើការប្រាស្រ័យទាក់ទងជាមួយភាគីតែម្ខាង, ចុះថ្ងៃទី២៥ មេសា ២០១២។ ឯកសារលេខ **E9/7/1/1/1/4** សេចក្ដីសម្រេចលើសេចក្ដីជូនដំណឹងពីរអំពីបណ្ដឹងសាទុក្ខ ដែលដាក់ដោយ អៀង សារី, ចុះថ្ងៃទី២៥ មេសា ២០១១, កថាខណ្ឌទី១៥ ("ជនជាប់ចោទខកខានក្នុងការបង្ហាញឱ្យឃើញថា តើការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង* បានបណ្ដាលឱ្យមានការបដិសេធសិទ្ធិរបស់គាត់យ៉ាងដូចម្ដេចខ្លះនោះទេ ឬថាតើការប្រព្រឹត្តិនេះគឺនាំឱ្យឈានទៅដល់កាលៈទេសៈពិសេសដោយឡែកមួយដែលតម្រូវឱ្យអង្គជំនុំជម្រះត្រូវតែទទួលយកបណ្ដឹងសាទុក្ខតាមវិធាន២១នៃវិធានផ្ទៃក្នុងយ៉ាងដូចម្ដេចខ្លះ")។ ឯកសារលេខ **E95/8/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី១៩ មីនា ២០១២, កថាខណ្ឌទី៩-១០។

[20] ឯកសារលេខ **E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ធ្វើការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង*, ចុះថ្ងៃទី២៥ មេសា ២០១២, កថាខណ្ឌទី១៣។ ឯកសារលេខ **E137/5/1/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើញត្តិសុំប្ដឹងជំទាស់ដិតចិត្តលោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី១៧ មេសា ២០១២, កថាខណ្ឌទី១២។

បាន ប្រសិនបើ "មិនបានបង្ហាញពីការចោទប្រកាន់នានាដែលវិធាន៣៥ ជាក់ស្តែងមិនអាចយកមកអនុវត្តបាននោះ"[21] ។

១២- ស្រដៀងគ្នានេះ ដូចដែលបានពិភាក្សានៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខអនុលោមតាមវិធាន១០៤(៤)(ក) អង្គជំនុំជម្រះបានថ្លែងថា វិធាននេះត្រូវតែធ្វើការ "បកស្រាយឲ្យបានសមហេតុសមផល" ទៅតាមគោលបំណងរបស់វាជាជាងទៅតាមន័យពិតប្រាកដ ហើយគួរតែដាក់បញ្ចូលចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងដែលនៅក្នុងខណៈមិនទាន់ឈានទៅដល់ការបញ្ចប់ដំណើរការនីតិវិធីជាផ្លូវការទេ ទោះបីជាយ៉ាងណាក្តី "មិននាំមកនូវការសន្យាសន្មតជាក់លាក់មួយដែរ" ហើយហេតុដូចនេះ "បញ្ចប់ដោយប្រសិទ្ធភាពនូវដំណើរការនីតិវិធីកុំឲ្យបន្ត" និងរារាំងកុំឲ្យឈានដល់ការវិនិច្ឆ័យទៅលើអង្គសេចក្តី"[22]។

១៣- ផ្ទុយពីចម្លើយតប ការអះអាងរបស់អង្គជំនុំជម្រះដែលថាសវនាការនាពេលអនាគត នឹងត្រូវធ្វើឡើង និងថាគ្មានការចោទប្រកាន់ណា "ត្រូវបានផ្អាកដោយសារតែផលវិបាកនៃដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនោះឡើយ"[23] គឺមិនមែនជាការដោះស្រាយបញ្ចប់បញ្ហាស្តីពីការបញ្ចប់ដោយប្រសិទ្ធភាពដូចដែលដែលអង្គជំនុំជម្រះសាលាដំបូងបានថ្លែងដោយច្បាស់ៗ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហាខាងកាយសម្បទា និងខាងសតិបញ្ញាស្មារតីដែល "ដំណើរការនីតិវិធីត្រូវបានផ្អាក និងមិនត្រូវបានបញ្ចប់នោះឡើយ"[24]។ ផ្ទុយទៅវិញ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះ គឺថាតើ "អានុភាព"នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺត្រូវបញ្ចប់ដំណើរការនីតិវិធីដែលទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មស្រុក១២ និងមន្ទីរស-២១ ដែរ ឬក៏អត់។

---

[21] ឯកសារលេខE137/5/1/3សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិសុំប្តឹងជំទាស់ដិតចិត្តលោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី១៧ មេសា ២០១២, កថាខណ្ឌទី១១-១២។

[22] ឯកសារលេខ E138/1/7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី១៣ ធ្នូ ២០១១, កថាខណ្ឌទី១៥។

[23] ឯកសារលេខ E163/5/1/3 ចម្លើយតប , កថាខណ្ឌទី៣៣។

[24] ឯកសារលេខ E138 សេចក្តីសម្រេចស្តីពីបញ្ហាខាងកាយសម្បទា និងខាងសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ, ចុះថ្ងៃទី១៧ វិច្ឆិកា ២០១១, កថាខណ្ឌទី៦៤។

១៤- ក្នុងន័យនេះ ភាគី (រួមទាំងមេធាវីការពារក្តី អៀង សារី ផង) បានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា នាពេលបច្ចុប្បន្ននេះ ពុំមានមានលទ្ធភាពជាក់ស្តែងនៃសវនាការនាពេលអនាគត ចំពោះជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនានា ដែលអង្គជំនុំជម្រះសាលាដំបូងបានបំបែកនោះឡើយ។ មេធាវីការពារក្តី អៀង សារី បានអះអាងថា "បើផ្អែកលើភ័ស្តុតាងពាក់ព័ន្ធ និងអាយុរបស់ជនជាប់ចោទ" ក្តីសង្ឃឹមក្នុងការជំនុំជម្រះសំណុំរឿង០០២ ដែលនៅសេសសល់គឺ "សូន្យ" ឬ ជា "ការស្រមើស្រមៃ"[25] ប៉ុណ្ណោះ។ មេធាវីការពារក្តី នួន ជា បានអះអាងថា៖ "ខ្ញុំគិតថា យើងគួរកំណត់សញ្ញាណមួយដាច់ខាតតែម្តង និងសម្រាប់ទស្សនៈទាំងអស់ដែលថានឹងមានសវនាការមួយទៀតក្នុងសំណុំរឿង០០២។ ច្បាស់ណាស់ យើងនៅជាប់ជាមួយសំណុំរឿង០០២/០១ ជាសវនាការដែលយើងកំពុងស្តាប់សក្ខីកម្មនាពេលនេះ និងមិនមានសវនាការមួយទៀតទេ។ ខ្ញុំគិតថា អ្នកទាំងអស់គ្នានឹងយល់ស្របជាមួយបញ្ហានេះដែរ"[26]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ផងដែរពីការយល់ស្របរបស់ខ្លួនជាមួយនឹងសេចក្តីសន្និដ្ឋាននេះ[27]។

១៥- ផ្ទុយពីចម្លើយតប បណ្តឹងសាទុក្ខបន្ទាប់ពីមានសាលក្រមនឹងពុំមានគោលដៅអ្វីទេ ហើយក៏មិនអាចការពារបានពេញលេញដល់ផលប្រយោជន៍របស់ជនរងគ្រោះ និងសហព្រះរាជអាជ្ញាទេ។ ដូចដែលភាគី និងអ្នកសង្កេតការណ៍បានយល់ស្របគ្នារួចហើយ គឺថាប្រសិនបើសវនាការទីពីរប្រឆាំងនឹងជនជាប់ចោទទាំងនេះមិនអាចធ្វើទៅបាននោះ បណ្តឹងសាទុក្ខលើសាលក្រមនឹងមិនអាចដោះស្រាយកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានដែរ។ បណ្តឹងសាទុក្ខភ្លាមៗគឺជាដំណោះស្រាយតែមួយគត់ដែលអាចការពារផលប្រយោជន៍ជនរងគ្រោះ និងសហព្រះរាជអាជ្ញា ដោយសម្រេចក្នុងខណៈដែលសវនាការកំពុងតែប្រព្រឹត្តទៅ ថាតើឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅស្រុក១២ និងមន្ទីរស-២១ គួរត្រូវយកមកជំនុំជម្រះ ដោយផ្អែកលើអង្គសេចក្តីជាផ្នែកមួយនៃសវនាការនេះ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលមិនអាចបើសវនាការ*សាជាថ្មី (de novo)* ដើម្បីស្តាប់សក្ខីកម្មភ័ស្តុតាង

---

25 Julia Wallace, "យុត្តិធម៌ក្នុងក្រចកសេះនៅតុលាការខ្មែរក្រហម" ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១២ *អាចរកមើលបាននៅ ៖* http://www.aljazeera.com/indepth/features/2012/09/2012925141556917463.html។

26 ប្រតិចារឹក, ឯកសារ **E1/136.1**, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២, ទំព័រ ៩ បន្ទាត់ ៣ ដល់ ១២។

27 សារណាគាំទ្ររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១, ឯកសារ **E163/5/1/5**, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៦។

ទាំងអស់ដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅស្រុក១២ និងមន្ទីរស-២១ ដូចដែលមេធាវីការពារក្តីបានស្នើឡើង[28]។

១៦- សហព្រះរាជអាជ្ញាក៏ជំទាស់ទៅនឹងការអះអាងរបស់មេធាវីការពារក្តីពី "ការយកចិត្តទុកដាក់មិនស្មើគ្នា" ដែលថាបណ្តឹងសាទុក្ខរបស់ខ្លួនត្រូវបានសន្និដ្ឋានថា មិនអាចទទួលយកបានដោយសារវិធាន១០៤(៤)ត្រូវបាន"បកស្រាយតាមន័យចង្អៀត"[29]។ មេធាវីការពារក្តីមានបំណងប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ឱ្យសម្រេចបដិសេធការស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ, និងដីកាបង្គាប់ឱ្យ អៀង សារី ត្រូវចូលរួមផ្តល់សេចក្តីសន្និដ្ឋានបើក និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងតាមសារអេឡិចត្រូនិករវាងមន្ត្រីច្បាប់ជាន់ខ្ពស់និងភាគី។ អង្គជំនុំជម្រះបានសន្និដ្ឋានថាបណ្តឹងសាទុក្ខបែបនេះចេញឆ្ងាយពីដែនកំណត់នៃវិធាន១០៤(៤)[30]។ អង្គជំនុំជម្រះបានសម្រេចស្រដៀងគ្នាដែរនៅពេល ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងសាទុក្ខ ចំពោះសេចក្តីសម្រេចមួយ ដែលពាក់ព័ន្ធនឹងរបាយការណ៍វេជ្ជសាស្ត្រ[31]។

១៧- ក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការលើកលែងទោស និងលក្ខខណ្ឌតម្រូវសម្រាប់ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាមួយជម្លោះប្រដាប់អាវុធនោះ មេធាវីការពារក្តីមិនអាចផ្តល់ទឡ្ហីករណ៍ដោយសុច្ចចិត្ត ថាសេចក្តីសម្រេចទាំងនោះមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីឡើយ។ ផ្ទុយទៅវិញ មេធាវីការពារក្តីគ្រាន់តែផ្តល់ទឡ្ហីករណ៍បែបសម្មតិកម្មថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្សេងពីនេះ ដោយផ្តល់ប្រយោជន៍ដល់ខ្លួនវិញនោះ សេចក្តីសម្រេចបែបនេះនឹងបញ្ចប់កិច្ចដំណើរការនីតិវិធី[32]។ អង្គជំនុំជម្រះតុលាការ

---

[28] ឯកសារ **E163/5/1/3** ចម្លើយតប កថាខណ្ឌ ៤១។

[29] ឯកសារ **E163/5/1/3** ចម្លើយតប កថាខណ្ឌ ៤៥។

[30] ឯកសារ **E9/7/1/1/1/4** សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ដោយ អៀង សារី, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១; សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ឯកសារ **E130/4/3**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២; សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនធ្វើការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង, ឯកសារ **E154/1/1/4**, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២។

[31] សេចក្តីសម្រេចស្តីពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ **E62/3/10/5/1**, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១១ ។

[32] ឯកសារ **E95/8/1/1** បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ផ្នែក III.ខ.២ ("សេចក្តីសម្រេចរងការជំទាស់ បានបញ្ចប់កិច្ចដំណើរការនីតិវិធី 'សវនាការដំណាក់កាលដំបូង'

កំពូលបានបដិសេធទឡ្ហីករណ៍នោះ ដោយសម្រេចថាគោលជំហររបស់មេធាវីការពារក្តី គឺជាការបកស្រាយដែលមិន “អាចការពារបាន” នូវវិធាន១០៤(៤)(ក) ដែលមានចេតនា “ធានាថាមធ្យោបាយក្នុងការប្តឹងសាទុក្ខពិតជាមាន នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ ដោយមិនទាន់មានការចេញសាលក្រម”[33]។ បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីទាំងនេះ មិនមានសទិសភាពជាមួយបញ្ហាភ្លាមៗនេះ ដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពិតជាបានបំបែកបទឧក្រិដ្ឋមួយចំនួនចេញពីកិច្ចដំណើរការនីតិវិធីដែលកំពុងតែបន្ត ក្នុងកាលៈទេសៈដែលមិនមានលទ្ធភាពអាចជឿបានថានឹងអាចបន្តទៅទៀតនៅពេលក្រោយ និងអាចធ្វើការជំនុំជម្រះលើអង្គសេចក្តីបានឡើយ។

១៨- ជាចុងក្រោយ មិនមានការសង្ស័យទេ ថាផលវិបាកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានពេលកំណត់ ពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលបានដកចេញនោះ “មានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់[34]” ដើម្បីធានាមានការត្រួតពិនិត្យបណ្តឹងសាទុក្ខភ្លាមៗ។ បញ្ហាដែលនៅចំពោះមុខ គឺថាតើជនជាប់ចោទនឹងត្រូវប្រឈមមុខការជំនុំជម្រះ ចំពោះបទចោទដែលធ្ងន់ធ្ងរបំផុត ដូចមានចែងក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែរ ឬទេ។ លទ្ធផលនៃបញ្ហានេះ គឺមិនអាចមានលក្ខណៈ “ធ្ងន់ធ្ងរ”ជាងឡើយ។

ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ”); បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស), ឯកសារ **E51/15/1/1**, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ៩។

[33] ឯកសារ **E95/8/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៨ ដល់ ៩។

[34] ឯកសារ **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ១៥។

## III. សេចក្ដីសន្និដ្ឋាន

១៩- ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើដោយក្ដីគោរពដល់អង្គជំនុំជម្រះសាលាដំបូង មេត្ដាបដិសេធនូវទឡ្ហីករណ៍ដែលលើកឡើងដោយមេធាវីការពារក្ដី អៀង សារី នៅក្នុងចម្លើយតបរបស់ខ្លួន ហើយមេត្ដាសម្រេចថាបណ្ដឹងសាទុក្ខភ្លាមៗនេះ អាចទទួលយកបាន។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |